ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការទទួលស្គាល់វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្ដីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា "វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី" ដែលមានអក្សរកាត់ "វ.វ.ប.អ." និងជាភាសាអង់គ្លេស "Australian Institute of Science and Technology" ដែលមានអក្សរកាត់ "AIST"។

**មាត្រា២.-**

វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានទីតាំងស្ថិតនៅភូមិប៉ាយាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣.-**

វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានភារកិច្ចធ្វើការបណ្តុះបណ្តាលៈ

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត
- កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៤៥ក្រេឌីត។

**មាត្រា៤.-**

វិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី ធ្វើការបណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោមៈ

- គ្រប់គ្រង
- បដិសណ្ឋារកិច្ចនិងគ្រប់គ្រងទេសចរណ៍
- រដ្ឋបាលសាធារណៈ
- វិទ្យាសាស្ត្រកុំព្យូទ័រ
- ស្ថាបត្យកម្ម
- គ្រប់គ្រងនិងសហគ្រិនភាព
- គណនេយ្យ
- គណនេយ្យនិងសវនកម្ម
- ធនាគារ ហិរញ្ញវត្ថុ និងមីក្រូហិរញ្ញវត្ថុ
- ហិរញ្ញវត្ថុនិងធានារ៉ាប់រង
- ម៉ាឃីតធីងនិងការគ្រប់គ្រង
- អប់រំ
- គណនេយ្យនិងហិរញ្ញវត្ថុ
- ពន្ធដារនិងសវនកម្ម
- អក្សរសាស្ត្រអង់គ្លេស
- ព័ត៌មានវិទ្យា
- វិស្វកម្មសំណង់ស៊ីវិល
- ទីផ្សារនិងស្រាវជ្រាវ
- គណនេយ្យនិងពន្ធដារ
- គណនេយ្យ សវនកម្ម និងពន្ធដារ
- ហិរញ្ញវត្ថុនិងទីផ្សារមូលបត្រ
- ហិរញ្ញវត្ថុ ទីផ្សារមូលបត្រ និងធានារ៉ាប់រង
- ច្បាប់
- សុវត្ថិភាពព័ត៌មាននិងការបង្កើតកម្មវិធី/ស.ស

| | |
|---|---|
| - វិស្វកម្មមេកានិច | - ព័ត៌មាននិងបច្ចេកទេសវេបសាយ |
| - សរសេរកម្មវិធីនិងរចនាគេហទំព័រ | - ការគ្រប់គ្រងអាជីវកម្មខ្នាតតូច |
| - ស្ថាបត្យកម្មតុបតែងនិងការរចនាផ្ទៃខាងក្នុង | - អចលនទ្រព្យនិងការវាយតម្លៃ |
| - ការគ្រប់គ្រងការសាងសង់ | - អគ្គិសនី |
| - អេឡិចត្រូនិច | - អាជីវកម្មនិងពាណិជ្ជកម្មអន្តរជាតិ |
| - ការគ្រប់គ្រងសេវាកម្មចំណីអាហារ | - ការដាំដុះនិងចិញ្ចឹម(ផ្នែកកសិកម្ម) |
| - រចនាផលិតផលនិងគ្រឿងសង្ហារិម | - ការរចនាសេរ៉ាមិច |
| - ការថតរូប ភាពយន្ត និងផលិតព័ត៌មាន | - គណនេយ្យនិងហិរញ្ញវត្ថុ |
| - ការរចនានិងផលិតព័ត៌មាន | - ការគ្រប់គ្រងភស្តុភា |
| - ការស្វែងរកទីផ្សារនិងការផ្សព្វផ្សាយពាណិជ្ជកម្ម | - ការរចនាម៉ូត។ |

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកសាខា ប្តូរទីតាំង ដេប៉ាតឺម៉ង់ថ្មី ឯកទេសថ្មី មហាវិទ្យាល័យ ដំឡើងកម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ឬបន្ថែមជំនាញផ្សេងៗទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

នាយកវិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី និងធានាឲ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្ស និស្សិតឲ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គោរពនិងអនុវត្តតាមការណែនាំនិងបទដ្ឋានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យបានទៀងទាត់តាមការកំណត់។/.

**មាត្រា៧ .-**

សិស្ស និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រឬសញ្ញាបត្រនេះត្រូវផ្ដល់ដោយវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកវិទ្យាស្ថាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអូស្ត្រាលី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ